# របាយការណ៍រួមរបស់ភាគីពាក់ព័ន្ធ
# ស្តីអំពីព័ត៌មាននៃស្ថានភាពយេនឌ័រនិងសិទ្ធិស្ត្រីនៅកម្ពុជា
# ផ្ញើជូនគណៈកម្មការត្រួតពិនិត្យ

មុនកាលបរិច្ឆេទនៃយន្តការពិនិត្យជាសកលតាមកាលកំណត់លើកទី៣របស់កម្ពុជា
នៅក្នុងកិច្ចប្រជុំលើកទី៣២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ
(ខែ មករា-កុម្ភៈ ឆ្នាំ២០១៩)

របាយការណ៍រួមផ្នែកនេះបានចូលរួមរៀបរាងនិងផ្ញើជូនដោយក្រុមអង្គការសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោម៖

១ អង្គការស៊ីដ កម្ពុជា(NGO-CEDAW)
២ អង្គការ អាក់សិនអេត (AAC)
៣ អង្គការអនាគតយុវជនអាស៊ាន(Cam-ASEAN)
៤ អង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
៥ បណ្តាញយេនឌ័រនិងការអភិវឌ្ឍន៍ (GADNet)
៦ DanChurchAid, Cambodia (DCA)
៧ អង្គការយុវជនខ្មែរ និងការអភិវឌ្ឍសង្គម(KYSD)
៨ ជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី (LSCW)
៩ សហគមន៍ឥន្ទ្រកម្ពុជា (RoCK)
១១ អង្គការសីលាកា (SILAKA)
១២ ផ្ទះសាមគ្គី (SC)
១៣ បណ្តាញការងារស្ត្រីរួបរួមគ្នា (WNU)

សម្រាប់សំណួរនិងព័ត៌មានបន្ថែមសូមទំនាក់ទំនង៖ អង្គការស៊ីដ កម្ពុជា(NGO-CEDAW)
# ១៦ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (ភាសាអង់គ្លេស)៖ +៨៥៥ ៨៥ ៤០០ ៩៤២ ទូរស័ព្ទ (ភាសាខ្មែរ)៖ +(៨៥៥) ១២ ៦៦៨ ៨៥៣
អ៊ីមែល៖ngocedaw.pnh@gmail.com

# 1. សេចក្តីផ្តើម

## 1.1 ទិដ្ឋភាពទូទៅអំពីយេនឌ័រនិងសិទ្ធិមនុស្សរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា

1.1.1 ប្រទេសកម្ពុជាមានការរីកចម្រើនជាច្រើនក្នុងផ្នែកសមភាពយេនឌ័រនិងសិទ្ធិស្ត្រី នៅក្នុងរយៈប៉ុន្មានឆ្នាំថ្មីៗនេះ ដោយរួមមានទាំង ការអនុម័តផែនការសកម្មភាពជាតិជាច្រើន ក្នុងការដោះស្រាយអំពើហិង្សាយេនឌ័រ និងសិទ្ធិការងារ។ ក៏ប៉ុន្តែ នៅតែមានបញ្ហាប្រឈមជាមូលដ្ឋានមួយចំនួន ដែលរារាំងដល់ការសម្រេចបានសមភាពជាសំខាន់ *(substantive equality)* រវាងបុរសនិងស្ត្រី។ សណ្ឋានបែបបទដែលមានភាពស៊ីសង្វាក់មួយនៅគ្រប់វិស័យនិងផ្នែកនានាក្នុងសង្គម គឺភាពមិនសាបសូន្យនៃផ្នត់គំនិតយេនឌ័រអវិជ្ជមាន។ ជំនឿដែលនៅតែបន្តកើតមានឡើងមិនដាច់ ដែលថាស្ត្រីមានសមត្ថភាពអន់ជាងបុរស និងការរំពឹងថា ស្ត្រីត្រូវសម្របខ្លួនតាមតួនាទីជាប្រពៃណីនៅក្នុងគ្រួសារនោះ បានដើរតួនាទីជាឧបសគ្គមួយរាំងខ្ទប់ការរីកចម្រើនក្នុងការអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៥ (សមភាពយេនឌ័រ)។ ឥរិយាបថទាំងនេះ ត្រូវបានប្រកាន់ខ្ជាប់ ដោយបុរសនិងស្ត្រីនិយោជកក្នុងវិស័យឯកជននិងសាធារណៈ អ្នកអប់រំ បុគ្គលិកវិជ្ជាជីវៈសុខាភិបាល មន្ត្រីអនុវត្តច្បាប់ និងអ្នកបម្រើការងារក្នុងអង្គការមិនមែនរដ្ឋាភិបាល។

1.1.2 ក្តីបារម្ភមួយទៀត គឺថា ថវិកានិងធនធានសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិ ត្រូវពឹងផ្អែកខ្លាំងទៅលើជំនួយពីអង្គការមិនមែនរដ្ឋាភិបាលនិងជំនួយអន្តរជាតិ។ ខណៈដែលសេដ្ឋកិច្ចកម្ពុជាផ្តល់នូវការលើកទឹកចិត្តនិងមានភាពរឹងមាំ និងបន្តកំណើន៧%ក្នុងមួយឆ្នាំនោះ ជំនួយបរទេសកំពុងមានការថយចុះ។ រដ្ឋាភិបាលកម្ពុជានឹងត្រូវបង្កើនតួនាទីរបស់ខ្លួនឲ្យបានកាន់តែខ្លាំង ប្រសិនបើការរីកចម្រើនទាំងនេះ ត្រូវធ្វើឲ្យសម្រេចបានក្នុងបរិយាកាសមួយ ដែលឥទ្ធិពលរបស់អង្គការមិនមែនរដ្ឋាភិបាលកំពុងតែរួញថយចុះជាងពេលណាៗទាំងអស់នោះ។ ត្រូវមានការប្តេជ្ញាចិត្តទាំងផ្នែកហិរញ្ញវត្ថុនិងធនធានមនុស្ស នៅគ្រប់ផ្នែកទាំងអស់របស់រដ្ឋាភិបាលដើម្បីធានាថា សិទ្ធិរបស់ស្ត្រីកម្ពុជាទាំងអស់ ត្រូវទទួលបានការការពារ និងធានាថា ភាពស្មើគ្នាផ្នែកយេនឌ័រ ក្លាយទៅជាការពិតនៅត្រឹមឆ្នាំ២០៣០នោះ។

## 1.2 វិធីសាស្ត្រ

1.2.1 នេះជារបាយការណ៍រួមរបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន១៣ ដែលបានចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា និងដែលកំពុងធ្វើការនៅក្នុងវិស័យយេនឌ័រនិងសិទ្ធិមនុស្សរបស់ស្ត្រី។[1]

1.2.2 របាយការណ៍នេះ ត្រូវបានសម្របសម្រួលដោយគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលនៃកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រីភេទ (NGO-CEDAW)។ អង្គការ NGO-CEDAW ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ និងមានឆន្ទៈក្នុងការតាមដានឃ្លាំមើលការអនុវត្តអនុសញ្ញា CEDAW ក្នុងប្រទេសកម្ពុជា។ អង្គការ NGO-CEDAW គឺជាសម្ព័ន្ធអង្គការសង្គមស៊ីវិលចំនួន៣៧ នៅក្នុងប្រទេសកម្ពុជា។ អង្គការ NGO-CEDAW ក៏បានដាក់របាយការណ៍មួយស្តីពីអំពើហិង្សាក្នុងគ្រួសារ សម្រាប់វដ្ត

UPR ជុំទីពីរក្នុងឆ្នាំ២០១៤ ដែរ។ ហើយបន្ថែមពីលើនេះ អង្គការ NGO-CEDAW ក៏បានដាក់របាយការណ៍ស្រមោលរួមលើប្រធានបទជាច្រើន ជូនទៅគណៈកម្មាធិការ ស៊ី ដ របស់អង្គការសហប្រជាជាតិ និងបានចូលរួមនៅក្នុងសម័យប្រជុំពិនិត្យរបាយការណ៍ ស៊ី ដ ចំនួនពីរដងដែរ។

1.2.3 ក្នុងការរៀបចំដាក់របាយការណ៍នេះ តំណាងរបស់អង្គការដែលចូលរួមដាក់របាយការណ៍នេះ បានជួបប្រជុំគ្នាជាច្រើនដង ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០១៨ ដើម្បីរៀបចំកិច្ចពិភាក្សាក្រុម ទៅលើប្រធានបទស្តីពីយេនឌ័រ និងដើម្បីជ្រើសរើសបញ្ហានានាយកមកពិភាក្សានៅក្នុងរបាយការណ៍នេះ។ ជាងនេះទៀត អង្គការចូលរួមដាក់របាយការណ៍ បានចូលរួមនៅក្នុងសិក្ខាសាលាចំនួនបី ក្នុងការជួបជុំក្រុមធំ (ចូលរួមដោយអង្គការសង្គមស៊ីវិលចំនួន៦០) ដែលរៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ប្រចាំនៅកម្ពុជា និង អង្គការ UPR Info ទៅលើបញ្ហាកាត់ទទឹងនានា។

## 2. ការណែនាំអំពីបរិបទ UPR នៅថ្នាក់ជាតិ

2.1 ប្រទេសកម្ពុជា បានទទួលការពិនិត្យរបាយការណ៍ក្នុងឆ្នាំ២០០៩ និង ២០១៤។ ក្នុងជុំទាំងពីរនេះ អនុសាសន៍ចំនួន៤២ ត្រូវបានលើកឡើងទាក់ទងនឹងយេនឌ័រនិងសិទ្ធិស្ត្រី (អនុសាសន៍ចំនួន៤០ ត្រូវបានគាំទ្រ និងចំនួន២ ត្រូវបានកត់សម្គាល់)។ យេនឌ័រ ស្ថិតនៅក្នុងចំណោមប្រធានបទចម្បងចំនួន៥ សម្រាប់អនុសាសន៍ដែលបានធ្វើឡើងក្នុងជុំទី១ និងជុំទី២ របស់ UPR។ បញ្ជីអនុសាសន៍ទាក់ទងនឹងប្រធានបទយេនឌ័រនិង/ឬសិទ្ធិស្ត្រី ត្រូវបានបញ្ចូលទៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយរបាយការណ៍។ ឧបសម្ព័ន្ធនេះ ក៏រួមមានអនុសាសន៍ដែលមិនបានបញ្ជាក់ជាពិសេសចំពោះស្ត្រី ប៉ុន្តែ មានការជាប់ទាក់ទងស្និទ្ធទៅនឹងអនុសាសន៍ដែលបានស្នើឡើង និងសំណួរត្រៀមទុកជាមុន ដែលមានរៀបរាប់នៅក្នុងការដាក់រាយការណ៍នេះ។ [2]

2.2 ក្នុងឆ្នាំ២០១៤ មានអនុសាសន៍ចំនួន២៤ ដែលត្រូវបានគាំទ្រ ផ្តោតទៅលើយេនឌ័រ/ក្មេងស្រី/ស្ត្រី និងអនុសាសន៍ចំនួន៥ ដែលត្រូវបានគាំទ្រ ជាប់ទាក់ទងនឹងសំណើអនុសាសន៍ថ្មី និងសំណួរត្រៀមទុកជាមុននៅក្នុងការដាក់របាយការណ៍នេះ។

2.3 ក្នុងចំណោមនោះ អនុសាសន៍ចំនួន១២ ត្រូវបានអនុវត្តពេញលេញឬស្ទើរតែពេញលេញ, អនុសាសន៍ចំនួន ៦ ត្រូវបានអនុវត្តខ្លះ និងអនុសាសន៍ចំនួន៥ មិនត្រូវបានអនុវត្តសោះឬស្ទើរតែគ្មានការអនុវត្ត។ អនុសាសន៍ដែលមិនត្រូវបានអនុវត្ត រួមមាន ១១៨.៥៣ សម្រាប់ច្បាប់ស្តីពីសមភាពយេនឌ័រ, ១១៨.៦៥ សម្រាប់កំណែទម្រង់ច្បាប់ទាក់ទងនឹងអំពើហិង្សាយេនឌ័រ, ១១៨.៩៤ ស្តីពីការទទួលបានយុត្តិធម៌, ១១៨.១៥០ ស្តីពីការថែទាំសុខភាពដោយមិនបង់កម្រៃសម្រាប់បុរសនិងស្ត្រីមានផ្ទុកមេរោគ/ជម្ងឺអេដស៍ (សេវានានា ត្រូវបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល ដែលជំនួយកាន់តែមានការថយចុះ), ១១៨.១៥១ ស្តីពីការកែលម្អការថែទាំសុខភាពបន្តពូជ និងការពន្យារកំណើតសម្រាប់ស្ត្រីជនបទ, និង១១៨.១១ ការផ្តល់អនុសាសន៍អំពីការអប់រំដាច់ខាត។

2.4 ក្នុងឆ្នាំ២០០៩ អនុសាសន៍ត្រូវបានគាំទ្រចំនួន១៦ អំពីយេនឌ័រ ត្រូវបានលើកឡើងក្នុងជុំទី១។ អនុសាសន៍ចំនួន៣ ក្នុងចំណោមនោះ រួមមានទាំងការផ្តល់សច្ចាប័នពិធីសារបន្ថែមនៃអនុសញ្ញា ស៊ី ដ ហើយការផ្តល់សច្ចាប័នបានកើតឡើងនៅឆ្នាំបន្ទាប់។

# 3 ប្រធានបទ៖ យេនឌ័រនិងសិទ្ធិស្ត្រី

3.1 ប្រទេសកម្ពុជា មានការកែលម្អដូចខាងក្រោម ចាប់តាំងពីជុំ UPR ចុងក្រោយមក៖

- ក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់រាយការណ៍អំពើហិង្សាលើស្ត្រី ត្រូវបានអនុម័តកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧
- ផែនការសកម្មជាតិលើកទីពីរ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ត្រូវបានអនុម័តកាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤
- ផែនការនារីរតនៈទី៤ (ផែនការសមភាពយេនឌ័ររួមសម្រាប់ថ្នាក់ជាតិ) ត្រូវបានអនុម័តក្នុងខែធ្នូឆ្នាំ ២០១៤
- ដាក់របាយការណ៍រដ្ឋក្នុងការតាមដានបន្ត ដល់គណៈកម្មាធិការ ស៊ី ដ ក្នុងខែកុម្ភៈ ឆ្នាំ២០១៦
- ដាក់របាយការណ៍រដ្ឋភាគីដល់គណៈកម្មាធិការ ស៊ី ដ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨
- ក្រសួងសុខាភិបាលនិងក្រសួងកិច្ចការនារីនៃប្រទេសកម្ពុជា បានប្រកាសឲ្យប្រើប្រាស់គោលការណ៍បញ្ជូនជាផ្លូវការសម្រាប់ស្ត្រីនិងកុមារីរងគ្រោះដោយសារអំពើហិង្សាយេនឌ័រក្នុងឆ្នាំ២០១៧។ ទន្ទឹមគ្នាដែរនោះ ក្រសួងទាំងពីរក៏បានប្រកាសដាក់ឲ្យប្រើប្រាស់ ស្តង់ដារអប្បបរមាសម្រាប់ការប្រឹក្សាជាមូលដ្ឋាន សម្រាប់ស្ត្រីនិងកុមារីរងគ្រោះដោយសារអំពើហិង្សាយេនឌ័រ
- ប្រទេសកម្ពុជា បានយល់ព្រមក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយរួមទាំងគោលដៅទី៥ ស្តីពី សមភាពយេនឌ័រ។

### 3.2 ថវិកាយេនឌ័រ

3.2.1 រដ្ឋាភិបាលកម្ពុជា បានអនុម័តផែនការសកម្មភាពនិងគោលនយោបាយជាតិជាច្រើន ដែលជាជំហានឆ្ពោះទៅមុខដ៏រឹងមាំមួយ ក្នុងការទទួលស្គាល់សិទ្ធិស្ត្រីក្នុងការទទួលបានសមភាពជាមួយបុរសលើគ្រប់វិស័យ។ ក៏ប៉ុន្តែមានបញ្ហាដ៏ចម្បងមួយក្នុងការអនុវត្តផែនការទាំងនេះឲ្យបានពេញលេញ។ មូលហេតុចម្បងមួយសម្រាប់បញ្ហានេះ គឺថា រដ្ឋាភិបាលកម្ពុជា មិនទាន់បានលះបង់គ្រប់គ្រាន់សម្រាប់ថវិកាដែលកំពុងមានការកើនឡើង សម្រាប់ការបណ្តុះបណ្តាល សម្រាប់ផ្នែកបច្ចេកវិទ្យា និងសម្រាប់បុគ្គលដែលជាតម្រូវការដើម្បីអនុវត្តឲ្យបានពេញលេញទៅលើផែនការនានា ដូចជា នារីរតនៈ (ផែនការសមភាពយេនឌ័រទាំងមូល) និង ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីនៅឡើយទេ។ មូលហេតុចម្បងទីពីរ គឺថា រដ្ឋាភិបាលកម្ពុជាបានដាក់ការទទួលខុសត្រូវភាគច្រើនបំផុតក្នុងការគ្រប់គ្រងផែនការទាំងនេះ ទៅលើក្រសួងកិច្ចការនារី ដែលមានថវិកាតិចតួច ធៀបនឹងការទទួលខុសត្រូវដ៏ធំធេងរបស់ខ្លួន។ ការផ្តល់មូលនិធិដល់ក្រសួងកិច្ចការនារី គួរត្រូវមានការពិនិត្យឡើងវិញនិង

បង្កើនជារៀងរាល់ឆ្នាំ។ ក្រសួងភាគច្រើន មិនបានប្រមូលទិន្នន័យអំពីយេនឌ័រទេ ហើយក៏មិនបានតាមដានការរីកចម្រើនទៅលើបញ្ហាយេនឌ័រ ឬរក្សាឲ្យបាននូវថវិកាគ្រប់គ្រាន់ដើម្បីធានាឲ្យមានការកែលម្អទៅលើបញ្ហាយេនឌ័រដែរ។ ថវិកាជាតិ មិនបានផ្តល់មូលនិធិសម្រាប់ការបញ្ជ្រាបយេនឌ័រឲ្យមានប្រសិទ្ធភាពនៅ ឡើយទេ។

3.2.2 ថ្មីៗនេះ រដ្ឋាភិបាលកម្ពុជា បានពង្រឹងការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការធ្វើវិមជ្ឈការ តាមរយៈការចេញអនុក្រឹត្យមួយ តម្រូវឲ្យមានភាគរយមួយនៃថវិកាជាតិ ផ្ទេរទៅក្នុងថវិកាឃុំសម្រាប់រយៈពេលប្រាំឆ្នាំ។ នេះជាការបង្ហាញនូវឱកាសមួយក្នុងការបង្កើនថវិកាឆ្លើយតបនឹងតម្រូវការយេនឌ័រនៅថ្នាក់មូលដ្ឋាន។ ក្នុងឆ្នាំ២០២០ ចំនួនទឹកប្រាក់ដែលត្រូវផ្ទេរនឹងស្មើ ៣.១% នៃថវិកាជាតិក្នុងឆ្នាំ២០១៩។[3] ថ្មីៗនេះ ប្រទេសកម្ពុជាមានប្រព័ន្ធគណៈកម្មាធិការកិច្ចការស្ត្រីនិងកុមារនៅថ្នាក់ឃុំ ដើម្បីដោះស្រាយបញ្ហាដែលប៉ះពាល់ដល់ស្ត្រីនិងកុមារនៅថ្នាក់មូលដ្ឋាន។ គណៈកម្មាធិការកិច្ចការស្ត្រីនិងកុមារនៅថ្នាក់ឃុំ បានចាប់យកការទទួលខុសត្រូវសម្រាប់ការផ្តល់សេវាសង្គម និងតួនាទីរបស់គណៈកម្មាធិការ មានការកើនឡើង ដោយសារតែការផ្តល់មូលនិធិពីអង្គការមិនមែនរដ្ឋាភិបាលមានការថយចុះ។[4] ប៉ុន្តែ ថវិកាឃុំ ច្រើនតែផ្តោតទៅលើហេដ្ឋារចនាសម្ព័ន្ធជាជាងសេវាសង្គម។ គណៈកម្មាធិការកិច្ចការស្ត្រីនិងកុមារនៅថ្នាក់ឃុំនិមួយៗ ត្រូវការ២០% នៃថវិកាអភិវឌ្ឍន៍ឃុំ ដើម្បីបំពេញតម្រូវការរបស់សហគមន៍ឲ្យកាន់តែមានប្រសិទ្ធភាព។[5]

3.2.3 ជាចុងក្រោយ ភាគច្រើននៃកម្មវិធីជាក់ស្តែងទាក់ទងនឹងផែនការសកម្មភាព និងដើម្បីឲ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ត្រូវបានផ្តល់មូលនិធិនិងអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាលបរទេសមួយចំនួន។[6] ការពឹងផ្អែកជ្រុលទៅលើអង្គការមិនមែនរដ្ឋាភិបាលក្នុងការផ្តល់សេវាមូលដ្ឋាន និងក្នុងការអនុវត្តកម្មវិធីដើម្បីឲ្យបានគោលដៅថ្នាក់ជាតិស្តីពីសមភាពយេនឌ័រ នាំឲ្យមានការអនុវត្តដែលមិនមានភាពស៊ីសង្វាក់ និងមិនពេញលេញ ទៅលើផែនការសកម្មភាព ដែលជាការអនុវត្តមានលក្ខណៈបណ្តោះអាសន្ន ក្នុងរយៈពេលមួយដែលអង្គការមិនមែនរដ្ឋាភិបាល ជារឿយៗ ទទួលបានការផ្តល់មូលនិធិសម្រាប់តែគម្រោងនិងកម្មវិធីសាកល្បងរយៈពេលខ្លីនោះ។ គម្រោងទាំងនេះ ទោះបីជាបានជោគជ័យខ្លាំងក៏ដោយ ក៏មិនបានបន្តទៅក្នុងឆ្នាំខាងមុខជាបន្តបន្ទាប់ដោយអង្គការមិនមែនរដ្ឋាភិបាល ឬចាប់យកទៅអនុវត្តបន្តដោយរដ្ឋាភិបាលដែរ ដោយសារតែខ្វះខាតការផ្តល់មូលនិធិ។ ឧទាហរណ៍ មានខ្សែទូរសព្ទបន្ទាន់ថ្នាក់ជាតិមួយ សម្រាប់បញ្ហាអំពើហិង្សាយេនឌ័រ ប៉ុន្តែ មិនមានអ្នកណាទទួលទូរសព្ទនេះឡើយ ចាប់តាំងពីរយៈពេលផ្តល់មូលនិធិរបស់កម្មវិធីបានបញ្ចប់ជាច្រើនឆ្នាំកន្លងផុតទៅហើយនោះ។

- **3.2.4 អនុសាសន៍ស្នើឡើង ដើម្បីដោះស្រាយបញ្ហាការផ្តល់ថវិកាឆ្លើយតបតម្រូវការយេនឌ័រ៖**
  - បង្កើតបន្ទាត់ថវិកាមួយសម្រាប់ការផ្តល់ថវិកាឆ្លើយតបតម្រូវការយេនឌ័រ សម្រាប់គ្រប់ក្រសួង/ភ្នាក់ងារនិមួយៗទាំងអស់នៅក្នុងថវិកាជាតិរបស់រដ្ឋាភិបាលនៅត្រឹមឆ្នាំ២០២០ និងបែងចែកផ្តល់៥% នៃថវិកាជាតិសរុបសម្រាប់បន្ទាត់ថវិកាទាំងនេះ។
  - អនុម័តរាល់វិធានការចាំបាច់នានា រួមទាំងបទប្បញ្ញត្តិនិងគោលនយោបាយ ឲ្យបានមុនសម័យប្រជុំពិនិត្យរបាយការណ៍បន្ទាប់ ដែលទាមទារឲ្យរដ្ឋបាលមូលដ្ឋានតាមឃុំ បែងចែកផ្តល់ថវិកា

អភិវឌ្ឍប្រចាំឆ្នាំចំនួន២០% ដើម្បីគាំទ្រដល់ការគ្រប់គ្រងរដ្ឋបាលនិងសកម្មភាពគណៈកម្មាធិការកិច្ចការស្ត្រីនិងកុមារនៅថ្នាក់ឃុំ។

- **3.2.5 សំណួរស្នើត្រៀមទុកជាមុន ទាក់ទងនឹងការធ្វើវិការឆ្លើយតបតម្រូវការយេនឌ័រ**

  តើរដ្ឋាភិបាលពិគ្រោះយោបល់និង/ឬឲ្យមានសង្គមស៊ីវិលចូលរួមដោយរបៀបណា ក្នុងការបញ្ជ្រាបយេនឌ័រ និងក្នុងការរៀបចំបង្កើតថវិកាថ្នាក់ជាតិ ជាពិសេសទាក់ទឹងនឹងការធ្វើថវិកាឆ្លើយតបនឹងតម្រូវការយេនឌ័រ?

## 3.3 កង្វះខាតសេវាសម្រាប់ជនរងគ្រោះពីអំពើហិង្សាយេនឌ័រ

3.3.1 រាល់ទម្រង់នៃអំពើហិង្សាយេនឌ័រនៅតែបន្តកើតមានជាធម្មតា។ ឧទាហរណ៍ មនុស្សជាច្រើននៅក្នុងសង្គមចាត់ទុកអំពើហិង្សាក្នុងគ្រួសារជាបញ្ហាគ្រួសារ ដែលត្រូវដោះស្រាយក្រៅផ្លូវការ ឬគាំទ្រទទួលយក ជាជាងការចាត់ទុកបទល្មើស។ ស្រដៀងគ្នានេះដែរ មានធនធានតិចតួចណាស់សម្រាប់ស្ត្រីដែលប្រឈមនឹងការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ។ ជនល្មើសរំលោភសេពសន្ថវៈ ជារឿយៗ មិនត្រូវបានទទួលទោសទណ្ឌឡើយ។

3.3.2 គ្មានជម្រកដែលគ្រប់គ្រងដោយរដ្ឋាភិបាល នៅក្នុងប្រទេសនៅឡើយទេ ហើយសេវាកម្មដែលរកបានមានកម្រិតតិចតួចណាស់។

3.3.3 កម្មវិធីមួយដែលអាចលុបបំបាត់ការខ្វះខាតសេវាកម្មសម្រាប់ជនរងគ្រោះដោយសារអំពើជួញដូរ និងអំពើហិង្សាយេនឌ័រ គឺជាមជ្ឈមណ្ឌលសេវាច្រកចូលតែមួយ។ ការសិក្សាសមិទ្ធិលទ្ធភាពមួយពីឆ្នាំ២០១១ បានស្នើឡើងថា ប្រទេសកម្ពុជា មិនទាន់ត្រៀមខ្លួនបានគ្រប់គ្រាន់ក្នុងការបង្កើតមណ្ឌលទាំងនេះនៅឡើយទេ ប៉ុន្តែ គួរចាប់ផ្តើមកម្មវិធីសាកល្បងមួយក្នុងរយៈប៉ុន្មានឆ្នាំខាងមុខ បន្ទាប់ពីកសាងសមត្ថភាពនិងអនុម័តរចនាសម្ព័ន្ធថ្នាក់ជាតិមួយសម្រាប់ដោះស្រាយអំពើហិង្សាយេនឌ័រ។ នាពេលបច្ចុប្បន្ននេះ ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល កំពុងធ្វើផែនការចាប់ផ្តើមកម្មវិធីសាកល្បងមួយនេះ។

3.3.4 បុគ្គលិកផ្នែកវេជ្ជសាស្ត្រ ជារឿយៗ ត្រូវបានគេរាយការណ៍ថា ច្រើនតែសើចចំអកដល់ស្ត្រីដែលស្វែងរកជំនួយនៅពេលមានរបួសដែលបណ្តាលមកពីអំពើហិង្សាយេនឌ័រ។ ពីមុន ឧបករណ៍សម្រាប់ធ្វើតេស្តការរំលោភសេពសន្ថវៈ មិនទាន់រកបានជាសាកលដោយមិនបង់កម្រៃនោះទេ។ រដ្ឋាភិបាលកំពុងរៀបចំផែនការដើម្បីធានាថា មានភាពងាយស្រួលក្នុងការទទួលបានការធ្វើតេស្តទាំងនេះ ប៉ុន្តែ នៅមិនទាន់ច្បាស់ថាតើ វានឹងមិនចាំបាច់បង់កម្រៃសម្រាប់ជនរងគ្រោះទាំងអស់ឬទេ។

3.3.5 មានការខ្វះខាតអ្នកឯកទេសវិកលវិទ្យានិងចិត្តវិទ្យានៅក្នុងប្រទេស ដែលមានសារៈសំខាន់ជាពិសេសចំពោះជនរងគ្រោះដោយសារអំពើហិង្សា ដែលជារឿយៗ ត្រូវការការព្យាបាលផ្នែកថប់បារម្ភ ឬផ្នែកការប៉ះទង្គិចផ្លូវចិត្ត។

3.3.6 អាជ្ញាធរ ដែលត្រូវបានទាក់ទងទៅ នៅពេលដែលជនរងគ្រោះនៃអំពើហិង្សា ស្វែងរកជំនួយ ជារឿយៗ ខ្វះជំនាញសម្ភាស និងការយល់ដឹងអំពីការផ្តល់ការប្រឹក្សាយោបល់។ ជារឿយៗ មានការរាយការណ៍ថា អាជ្ញាធរ ប្រើប្រាស់ពាក្យពេចន៍មាក់ងាយ បន្ទោសជនរងគ្រោះដោយសារអំពើហិង្សាដែលពួកគេបានទទួលរង។ ទោះបីជារដ្ឋាភិបាលបានបង្កើតសៀវភៅណែនាំអំពីការប្រឹក្សាយោបល់កាលពីឆ្នាំ២០១៧ ក៏ដោយ ក៏វាមានលក្ខណៈបច្ចេកទេស ពិបាកយល់ និងសម្រាប់គោលបំណងច្រើនយ៉ាង ដោយសារតែសៀវភៅនេះ គឺជាបណ្តុំបញ្ចូលគ្នាតែមួយសម្រាប់អ្នកវិជ្ជាជីវៈសុខាភិបាល អ្នកអនុវត្តច្បាប់ មន្ត្រីអង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាលផង។ ការបណ្តុះបណ្តាល ដែលផ្តោតទៅលើក្រុមនិមួយៗ គឺជាតម្រូវការនៅថ្នាក់ភូមិ ព្រមទាំងត្រូវការការវិនិយោគបន្ថែមទៀតពីរដ្ឋាភិបាល។ មានយន្តការផ្លូវច្បាប់តិចតួចបំផុត ដែលស្ត្រីប្រឈមអំពើហិង្សា អាចរកបាន។

3.3.7 ថ្វីត្បិតតែមានកិច្ចប្រឹងប្រែងកើនឡើង របស់រដ្ឋាភិបាលក្នុងការលើកកម្ពស់ការយល់ថា អំពើហិង្សាក្នុងគ្រួសារ ជាទង្វើខុសឆ្គងហើយក៏ដោយ ក៏គោលនយោបាយរដ្ឋាភិបាលទាំងនៅថ្នាក់មូលដ្ឋាននិងនៅថ្នាក់ជាតិ នៅតែបន្តប្រើប្រាស់ការសម្រុះសម្រួល ជាដំណោះស្រាយដែលគេចូលចិត្តប្រើបំផុត សម្រាប់ដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារដដែល។ ទោះបីជាច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ មានចែងអំពីប្រភេទនៃវិធានការការពារចំនួន២ (សេចក្តីសម្រេចរដ្ឋបាលដោយក្រុមប្រឹក្សាឃុំ និងដីកាការពាររបស់តុលាការ) ក៏ដោយ ក៏វិធីនៃការបង្កាទប់ស្កាត់អំពើហិង្សាលើដៃគូស្និទ្ធស្នាល មិនដែលបានតម្រូវចាំបាច់ដាច់ខាតដោយច្បាប់នេះឡើយ ហើយដូច្នេះគេកម្រប្រើវាណាស់ សូម្បីតែប្រើរួមគ្នាជាមួយការសម្រុះសម្រួលក៏កម្រដែរ។[7] ពីឆ្នាំ២០១៤ ដល់២០១៦ ជាមធ្យម មានការចេញដីកាការពារចំនួន៦ ក្នុងមួយឆ្នាំ។ មិនមានការការពារដែលបានចែងនៅក្នុងច្បាប់ស្តីពីអំពើហិង្សា សម្រាប់ស្ត្រីដែលមិនរស់នៅជាមួយដៃគូរបស់ខ្លួនឡើយ ដោយរួមទាំង អ្នកដែលត្រូវបានដៃគូ លបតាមដាន បន្ទាប់ពីស្ត្រីប៉ុនប៉ងចាកចេញពីដៃគូ។ រដ្ឋាភិបាលកម្ពុជា នឹងទទួលបានការសាទរ ចំពោះការដាក់បញ្ចូលផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបអំពើហិង្សាលើកុមារ វិសោធនកម្មមួយចំនួនទៅលើច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការជួញដូរ ក្រមរដ្ឋប្បវេណី និងការបន្ថែមបទប្បញ្ញត្តិមួយចំនួនដើម្បីបញ្ជាក់ឲ្យច្បាស់អំពីការប្រើប្រាស់សេចក្តីសម្រេចតាមផ្លូវរដ្ឋបាល។[8] ការធ្វើវិសោធនកម្មទាំងនេះ ក៏គួរបញ្ចូលបទប្បញ្ញត្តិនានា ដើម្បីការពារស្ត្រីនិងជនផ្សេងទៀតដែលប្រឈមនឹងអំពើហិង្សាដែរ។

3.3.8 ជាងនេះទៀត ប្រជាជនជាច្រើន មិនមានការជឿជាក់ទៅលើប្រព័ន្ធតុលាការទេ ហើយជារឿយៗ វាមិនបង្កលក្ខណៈងាយស្រួលដល់ស្ត្រីភាគច្រើន ជាពិសេស ស្ត្រីនៅតាមជនបទ។

3.3.9 មានមេធាវីតិចតួចណាស់នៅក្នុងប្រទេសនេះ ហើយជំនួយផ្នែកច្បាប់ដែលអាចរកបាន ក៏មានតិចតួចដែរ។ ថ្វីត្បិតតែមានការកើនឡើងបន្តិចបន្តួចទៅលើថវិកាជំនួយផ្នែកច្បាប់ក៏ដោយ ក៏ក្នុងចំណោមប្រជាជន ១៥,០០០ នាក់ មានមេធាវីតែម្នាក់ប៉ុណ្ណោះ នៅក្នុងប្រទេសកម្ពុជា។[9] ជាងនេះទៀត មេធាវីភាគច្រើន មាននៅក្នុងតំបន់ទីក្រុង ប៉ុន្តែ ប្រជាជនកម្ពុជាក្រីក្រភាគច្រើន រស់នៅក្នុងតំបន់ជនបទ។

3.3.10 កំណត់ត្រានិងស្ថិតិតុលាការ មិនទាន់អាចរកបាននៅឡើយទេ។ ខណៈដែលក្រសួងយុត្តិធម៌បានចាប់ផ្តើមដំណើរការបញ្ចូលប្រព័ន្ធកំណត់ត្រាតុលាការចូលក្នុងប្រព័ន្ធកុំព្យូទ័រនោះ ការប្រាស្រ័យទាក់ទងរវាងតុលាការនិងនាយកដ្ឋាននានា នៅមិនទាន់បានល្អនៅឡើយទេ ហើយមានតម្លាភាពតិចតួចណាស់ ទាក់ទងនឹងចំនួនព្រមទាំងលទ្ធផលនៃសំណុំរឿងតុលាការ ជាពិសេស សំណុំរឿងទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ។

3.3.11 កំណត់ត្រាភាគច្រើនមិនត្រូវបានបញ្ចេញសម្រាប់សំណុំរឿងទាំងនេះទេ សូម្បីតែបន្ទាប់ពីលុបឈ្មោះ ឬលុបព័ត៌មានអត្តសញ្ញាណផ្សេងៗទៀតក៏ដោយ។ ជាងនេះទៀត ដោយសារតែអំពើហិង្សាក្នុងគ្រួសារ មិនមែនជាបទល្មើសព្រហ្មទណ្ឌដាច់ដោយឡែកនោះ វាអាចនឹងមានការលំបាកក្នុងការប្រើប្រាស់ស្ថិតិដែលផ្អែកទៅលើបទចោទព្រហ្មទណ្ឌតែមួយ ក្នុងការញែកឲ្យដាច់រវាងអំពើហិង្សាក្នុងគ្រួសារនិងជនមិនដែលស្គាល់មុខ និងអំពើហិង្សាបង្កដោយជនមិនដែលស្គាល់មុខ។

3.3.12 ជាទូទៅ កំណែទម្រង់ទៅលើប្រព័ន្ធច្បាប់ ដើម្បីឲ្យប្រទេសកម្ពុជាអនុលោមតាមអនុសាសន៍ទូទៅលេខ ៣៣ នៃអនុសញ្ញា ស៊ី ដ មិនទាន់ត្រូវបានអនុវត្តនៅឡើយទេ។ របាយការណ៍ឆ្នាំ២០១៧ ដោយគណៈកម្មាធិការថៅក្រមអន្តរជាតិ បានធ្វើការសង្ខេបការស្រាវជ្រាវមួយ ដោយបានបង្ហាញអំពីភាពខ្វះខាតខ្លាំងនៅគ្រប់ដំណាក់កាលទាំងអស់នៃប្រព័ន្ធច្បាប់ក្នុងប្រទេសកម្ពុជា។ ដោយរាប់ចាប់តាំងពីការខ្វះខាតជំនួយផ្នែកច្បាប់ (រួមទាំងការសូកប៉ាន់, ប៉ូលីសយកចំណែកខ្លះនៃលុយដំណោះស្រាយ ព្រមទាំង ថៅក្រមនិងព្រះរាជអាជ្ញាដែលមានភាពលម្អៀង) រហូតដល់ការខ្វះខាតដំណោះស្រាយពិតប្រាកដនៅក្នុងប្រព័ន្ធតុលាការនោះ ប្រទេសកម្ពុជាបន្តខ្វះខាតនីតិរដ្ឋពិតប្រាកដ។[10] តាមពិតទៅ នៅក្នុងឆ្នាំ២០១៦ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី១១២ ក្នុងចំណោម ១១៣ នៅក្នុងលិបិក្រមនីតិរដ្ឋនៃគម្រោងយុត្តិធម៌ពិភពលោក។[11]

- **3.3.13 អនុសាសន៍ស្នើឡើង សម្រាប់ដោះស្រាយកង្វះខាតសេវាសម្រាប់អំពើហិង្សាយេនឌ័រ៖**
  បង្កើតនិងបែងចែកផ្តល់ក្នុងថវិកាជាតិ ឲ្យមានធនធានមនុស្សនិងហិរញ្ញវត្ថុឲ្យបានគ្រប់គ្រាន់ សម្រាប់រដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រងនិងប្រតិបត្តិការ យ៉ាងហោចណាស់ ទៅលើមណ្ឌលសេវាកម្មច្រកចេញចូលតែមួយយ៉ាងហោចណាស់ឲ្យបានប្រាំមណ្ឌលឲ្យបានមុនឆ្នាំ២០២៤ ដែលជាមណ្ឌលដែលផ្តល់នូវសេវាវេជ្ជសាស្ត្រ ផ្លូវច្បាប់ ចិត្តសាស្ត្រ និងសេដ្ឋកិច្ច (ជម្រក អាហារ ជំនួយប្រាក់កាស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការស្វែងរកការងារឲ្យធ្វើ) ដោយមិនគិតកម្រៃចំពោះជនរងគ្រោះ គ្រប់ទម្រង់នៃអំពើហិង្សាយេនឌ័រ ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ១៦.១)។

- **3.3.14 សំណួរស្នើត្រៀមទុកជាមុន ទាក់ទងនឹងសេវាកម្មសម្រាប់អំពើហិង្សាយេនឌ័រ**
តើមានគម្រោងពេលវេលាណា ដែលរដ្ឋាភិបាលដាក់ផែនការ និងសកម្មភាពអ្វីខ្លះដែលរដ្ឋាភិបាលកម្ពុជា បានចាត់ឡើង ដើម្បីបង្កើតមណ្ឌលសេវាកម្មច្រកចេញចូលតែមួយ សម្រាប់ជនរងគ្រោះនៃអំពើហិង្សាយេនឌ័រ ?

## 3.4 អ្នកដឹកនាំជាស្ត្រី

3.4.1 ស្ត្រីទទួលបានការងារធ្វើនៅខាងក្រៅផ្ទះ ក្នុងអាត្រាមួយដែលមានការកើនឡើង ប៉ុន្តែមិនទាន់មានតំណាងល្អគ្រប់គ្រាន់នៅកម្រិតធ្វើការសម្រេចចិត្តនៅឡើយទេ ជាពិសេស ក្នុងផ្នែកនយោបាយនិងក្នុងរដ្ឋាភិបាល។

3.4.2 រដ្ឋាភិបាលកម្ពុជា គួរទទួលបានការកោតសរសើរដោយសារការទទួលយកជាបន្តបន្ទាប់នូវគោលដៅនានាដោយស្ម័គ្រចិត្ត ដែលបានប្រកាសនៅក្នុងសន្និសីទសារព័ត៌មាន ផែនការសកម្មភាព និងគោលនយោបាយ ក្នុងការបង្កើនចំនួនស្ត្រីក្នុងការិយាល័យនយោបាយនិងក្នុងសេវាពលរដ្ឋ ទាំងក្នុងការជ្រើសតាំងតាមរយៈការបោះឆ្នោត និងការតែងតាំង។ វិធានការបែបនេះ មានភាពចាំបាច់ ក្នុងការអនុវត្តឲ្យបានពេញលេញនូវអនុសញ្ញា ស៊ី ដ និងដើម្បីបង្ហាញចេតនាល្អរបស់រដ្ឋាភិបាលកម្ពុជា សំដៅសម្រេចឲ្យបាននូវកាតព្វកិច្ចតាមសន្ធិសញ្ញា។ ក៏ប៉ុន្តែមិនមានអាណត្តិផ្លូវច្បាប់ឬការគាំទ្រថវិកាណាមួយ សម្រាប់ការតំណាងរបស់ស្ត្រីនៅក្នុងអភិបាលកិច្ចនយោបាយនៅថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិនៅក្នុងប្រទេសកម្ពុជានៅឡើយទេ។ ដូច្នេះ គោលដៅស្ម័គ្រចិត្តទាំងនេះ ជារឿយៗមិនបានសម្រេចទេ ហើយមិនមានផលវិបាកអ្វីចំពោះការខកខានមិនបានសម្រេចនូវគោលដៅទាំងនេះឡើយ។

| | គោលដៅ[12] | | | ជាក់ស្តែង | | |
|---|---|---|---|---|---|---|
| | គោលដៅអភិវឌ្ឍសហសវត្សកម្ពុជាឆ្នាំ 2015 | នារីរតនៈ 2018 | គោលដៅអភិវឌ្ឍប្រកបដោយចីរភាព 2030 | 2016 | ក្រោយការបោះឆ្នោតមូលដ្ឋានឆ្នាំ 2017 | ការបែងចែកអាសនៈរបស់គណៈបក្សប្រឆាំងក្រោយឆ្នាំ ២០១៨ និងការបោះឆ្នោតព្រឹទ្ធសភា[13] |
| ព្រឹទ្ធសភា | 30% | 30% | 50% | 14.75% | 14.75% | 14% |
| រដ្ឋសភា | 30% | 30% | 50% | 20.33% | 20.33% | 15% |
| តំណាងថ្នាក់ក្រសួង | 15% | | 50% | 10.70% | 10.70% | |
| រដ្ឋលេខាធិការ | 18% | - | 50% | 20.54% | 20.54% | |
| អនុរដ្ឋលេខាធិការ | 20% | - | 50% | 17.60% | 17.60% | |
| អភិបាលខេត្ត | 10% | - | 50% | 0% | 4%[14] | |
| អភិបាលខេត្តរង | 15% | - | 50% | 20% | 20% | |
| អភិបាលស្រុក | | - | 50% | 1% | 1% | |
| អភិបាលរងស្រុក | | - | 50% | 29% | | |
| ក្រុមប្រឹក្សាឃុំ/សង្កាត់ | 25% | 25% | 50% | 17.78% | 16.76% | ក្នុងតំណែងថ្នាក់មូលដ្ឋានទាំងអស់, ២០% ជាស្ត្រី និង ៨% ជាមេឃុំស្ត្រី[15] |

3.4.3 អ្នកដឹកនាំនយោបាយ ជារឿយៗ អះអាងថា ស្ត្រីមិនមានតំណាងគ្រប់គ្រាន់នៅក្នុងនយោបាយទេ ពីព្រោះស្ត្រីមិនទាន់មានគុណសម្បត្តិគ្រប់គ្រាន់។[16] ក៏ប៉ុន្តែ ទឡ្ហីករណ៍នេះ ត្រូវបានបដិសេធដោយគណៈកម្មាធិការអនុសញ្ញា ស៊ី ដ នៅក្នុងអនុសាសន៍ទូទៅលេខ២៥។[17]

3.4.4 ផ្ទត់គំនិតនិងទំនៀមអវិជ្ជមានទៅលើយេនឌ័រ បានរួមចំណែកដល់ការបង្កើតឲ្យមានលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសដែលមានភាពរើសអើង ដោយអ្នកដឹកនាំគណបក្សនយោបាយនៃគ្រប់គណបក្សនយោបាយចម្បងៗទាំងអស់។ រចនាសម្ព័ន្ធអំណាចដែលត្រួតត្រាដោយបុរសនៅក្នុងគណបក្សនយោបាយ ធ្វើឲ្យបេក្ខជនស្ត្រី មានការលំបាក ដោយមិនដឹងច្បាស់ប្រាកដអំពីការតែងតាំងឈ្មោះរបស់ខ្លួននៅលេខរៀងខាងលើក្នុងបញ្ជីឈ្មោះ។ លក្ខណៈវិនិច្ឆ័យ ដែលគណបក្សនយោបាយនិងមន្ត្រីរដ្ឋាភិបាលប្រើប្រាស់នោះក្នុងពង្រឹងអំណាចនៃការតែងតាំងនេះ មានឥទ្ធិពលក្នុងការផាត់ស្ត្រីភាគច្រើន ចេញពីដំណើរការនយោបាយ មិនថាអ្នកដឹកនាំមានឬមិនមានចេតនា ក្នុងការរើសអើងស្ត្រីនោះទេ។ ដើម្បីទប់ទល់នឹងភាពលម្អៀងលាក់មុខបែបនេះ ត្រូវមានវិធានការដាច់ខាតឬវិធានការពិសេសបណ្តោះអាសន្ន ដើម្បីដាក់ស្ត្រីនៅក្នុងមុខតំណែងនៃភាពជាអ្នកដឹកនាំនៅក្នុងស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នរដ្ឋបាល និងស្ថាប័នតុលាការនៃរដ្ឋាភិបាល។ ការដាក់ស្ត្រីទៅក្នុងតំណែងដែលមានអំណាចកាន់តែឆាប់កាលណា វត្តមានរបស់ស្ត្រីនឹងអាចធ្វើឲ្យមានការផ្លាស់ប្តូរក្រឹត្យក្រមយេនឌ័រកាន់តែឆាប់ដែរ ព្រមទាំងលើកទឹកចិត្តដល់អ្នកដឹកនាំជាស្ត្រីជំនាន់ថ្មីដែរ។

- **3.4.5 អនុសាសន៍ស្នើឡើង សម្រាប់ដោះស្រាយកង្វះខាតស្ត្រីក្នុងថ្នាក់ដឹកនាំៈ**
  អនុម័តវិធានការផ្លូវច្បាប់និងដាក់ស្តែងប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថា តំណែងធ្វើការសម្រេចចិត្តចំនួន៣៥% ត្រូវបំពេញដោយស្ត្រីឲ្យបានមុនឆ្នាំ២០២៣ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយរួមទាំងនៅក្នុងសេវាពលរដ្ឋ តំណែងការិយាល័យដែលជាប់ដោយការបោះឆ្នោត និងគ្រប់ផ្នែកនៃប្រព័ន្ធយុត្តិធម៌ ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ៥.៥។

- **3.4.6 សំណួរស្នើត្រៀមទុកជាមុន ទាក់ទងនឹងស្ត្រីក្នុងភាពជាអ្នកដឹកនាំ**
  **តើមានយន្តការអ្វីខ្លះដែលត្រូវអនុវត្តដើម្បីធានាថា គោលដៅសម្រាប់ភាគរយស្ត្រីនៅក្នុងតួនាទីភាពជាអ្នកដឹកនាំ បានសម្រេច មុនកាលបរិច្ឆេទកំណត់ ដែលប្រទេសកម្ពុជាបានទទួលយកនៅក្នុងវដ្ត** UPR **នេះ**?

## 3.5 ស្ត្រីនៅក្នុងពន្ធនាគារ

3.5.1 នៅចុងឆ្នាំ២០១៦ និងពេញមួយឆ្នាំ២០១៧ រដ្ឋាភិបាលកម្ពុជា បានចូលរួមពាក់ព័ន្ធនៅក្នុងយុទ្ធនាការកម្រិតខ្ពស់មួយ ប្រឆាំងនឹងការជួញដូរនិងការប្រើប្រាស់ថ្នាំញៀននៅក្នុងប្រទេសកម្ពុជា ដែលធ្វើឲ្យសង្គមកាន់តែមានសុវត្ថិភាព។ ក៏ប៉ុន្តែ វិធីសាស្ត្រដែលបានប្រើ បានបណ្តាលឲ្យមានការកើនឡើងច្រើននៃចំនួនស្ត្រីនៅក្នុងពន្ធនាគារទៅវិញ។[18] ជំនួសឲ្យការផ្តល់ជម្រើសក្នុងការព្យាបាលសម្រាប់ស្ត្រីកម្ពុជាដែលកំពុងប្រើប្រាស់ថ្នាំញៀន រដ្ឋាភិបាល ជារឿយៗ បែរជាបញ្ជូនពួកគេទៅពន្ធនាគារដោយផ្ទាល់ទៅវិញ។ ពន្ធនាគារដែលមានភាពចង្អៀតណែនស្រាប់ហើយនោះ បានកើនឡើងយ៉ាងគំហុកនូវចំនួនអ្នកជាប់ក្នុងពន្ធនាគារចំនួន២០% បន្ថែមទៀត។[19] សមត្ថភាពផ្ទុកនៅក្នុងពន្ធនាគារជាច្រើន មានកម្រិតលើស ២០០% ដោយរួមទាំងមណ្ឌល ម២ សម្រាប់តែអ្នកទោសស្ត្រី ផ្ទុករហូតដល់ទៅ ២៥៧%។[20]

3.5.2 ក្ដីបារម្ភជាពិសេសនោះ គឺចំនួនខ្ពស់នៃអ្នកជាប់ឃុំបណ្ដោះអាសន្ននៅក្នុងពន្ធនាគារ (ដែលមានចំនួនច្រើនជាង ៣០% នៃចំនួនសរុបទាំងបុរសនិងស្ត្រី[21]) ទោះបីជាមាននីតិវិធីជាលាយលក្ខណ៍អក្សរក្នុងការកាត់បន្ថយចំនួននេះ ក្នុងនោះ រួមមានដូចជា មាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានចែងថា ជាទូទៅ "ជនត្រូវចោទ ត្រូវមានសេរីភាព" និងមាត្រា២០៤ ដែលកំណត់ឲ្យមានការឃុំខ្លួនបណ្ដោះអាសន្ន សម្រាប់តែបទចោទណាដែលនឹងត្រូវមានទោសអប្បបរមាចំនួនមួយឆ្នាំតែប៉ុណ្ណោះក៏ដោយ។ ទោះបីជាច្បាប់បានលើកឡើងថាការឃុំខ្លួនបណ្ដោះអាសន្ន គួរប្រើតែនៅពេលដែលកាលៈទេសៈពិសេសតម្រូវក៏ដោយ ក៏ក្នុងការអនុវត្តជាក់ស្ដែងមានការឃុំខ្លួនមនុស្សភាគច្រើន មុនការជំនុំជម្រះដដែល។[22] ក្នុងឆ្នាំ២០១៧ ចំនួននេះ រួមបញ្ចូលទាំង បុគ្គលដែលត្រូវចោទពីបទប្រើប្រាស់គ្រឿងញៀនប៉ុន្តែមិនបានលក់គ្រឿងញៀនទេ និងមនុស្សដែលត្រូវចោទថាបានផ្សព្វផ្សាយក្នុង Facebook ដែលប្រមាថដល់រដ្ឋាភិបាលទៀតផង។

3.5.3 ក្ដីបារម្ភមួយដែរនោះ គឺការកើនឡើងនៃស្ត្រីមានផ្ទៃពោះដែលជាប់ពន្ធនាគារ និងកុមារដែលកំពុងរស់នៅជាមួយម្ដាយនៅក្នុងពន្ធនាគារ។[23] ច្បាប់ស្ដីពីពន្ធនាគាររបស់ប្រទេសកម្ពុជា អនុញ្ញាតិឲ្យម្ដាយដែលមានកូនអាយុក្រោម៣ឆ្នាំ រស់នៅជាមួយកូននៅក្នុងពន្ធនាគារ។[24] មាត្រា៤១ នៃច្បាប់ស្ដីពីពន្ធនាគារ អនុសញ្ញាស្ដីពីសិទ្ធិកុមារ និងវិធានក្រុងបាងកក តម្រូវឲ្យរដ្ឋ ចេញថ្លៃការចំណាយសម្រាប់ការថែទាំកុមារទាំងនេះ ប៉ុន្តែក្នុងការអនុវត្តជាក់ស្ដែង រដ្ឋាភិបាលបានផ្ដល់ចំនួនតែ ០.៣៥ ដុល្លា ប៉ុណ្ណោះសម្រាប់កុមារម្នាក់ក្នុងមួយថ្ងៃ ហើយម្ដាយត្រូវបង្ខំចិត្តចំណាយសម្រាប់តម្រូវការចាំបាច់ជាមូលដ្ឋាននានា។ មានពេលខ្លះ អ្នកជាប់ពន្ធនាគារនិងកុមារ ត្រូវដេកនៅលើកម្រាលឥដ្ឋផ្ទាល់ និងមិនមានម្ហូបអាហារ ទឹកស្អាតសម្រាប់ផឹក ឬការថែទាំសុខភាពឲ្យបានទៀងទាត់គ្រប់គ្រាន់នោះទេ។ ម្ដាយដែលទើបបង្កើតកូន មិនបានទទួលការថែទាំក្រោយសម្រាលទេ។ ស្ត្រីមានផ្ទៃពោះនិងស្ត្រីកំពុងបំបៅដោះកូន មិនបានទទួលអាហារបំប៉នដែលមានជីវជាតិគ្រប់គ្រាន់នោះទេ។ តម្រូវការអនាម័យជាមូលដ្ឋានដូចជា សាប៊ូ សំឡីអនាម័យ និងកន្លែងរស់នៅស្អាត មិនមានគ្រប់គ្រាន់ទេ។ ជារឿយៗ កុមារមិនបានចេញមកធ្វើលំហាត់ប្រាណទេ ហើយត្រូវនៅក្នុងបន្ទប់ឃុំឃាំងចង្អៀតណែនណាន់តាន់តាប់ ដោយគ្មានពន្លឺព្រះអាទិត្យឬសកម្មភាពអ្វីទេ។[25]

- **3.5.4 អនុសាសន៍ស្នើឡើង ដើម្បីដោះស្រាយលក្ខខណ្ឌស្ថានភាពស្ត្រីក្នុងពន្ធនាគារ៖**
  បញ្ឈប់ការដាក់ឃុំខ្លួនបណ្ដោះអាសន្នក្នុងពន្ធនាគារ ទៅលើស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលកំពុងរស់នៅជាមួយកូន ឲ្យបានត្រឹមឆ្នាំ២០២០។

- **3.5.5 សំណួរស្នើត្រៀមទុកជាមុន ទាក់ទងនឹងស្ត្រីក្នុងពន្ធនាគារ៖**
  តើប្រទេសកម្ពុជាធ្វើដូចម្ដេច ដើម្បីធានាថាស្ត្រី មិនត្រូវបានចោទប្រកាន់ដោយគ្មានភស្ដុតាងថាពួកគេបានប្រព្រឹត្តបទល្មើសនោះ?

### 3.6 ការរើសអើងទៅលើអ្នកផ្ដល់សេវាផ្លូវភេទ

3.6.1 ច្បាប់ព្រហ្មទណ្ឌនិងច្បាប់ប្រឆាំងការជួញដូររបស់ប្រទេសកម្ពុជា ផ្តោតទៅលើការកាត់ទោសនិងរឹតបណ្តឹងទៅលើអ្នកដែលកេងប្រវ័ញ្ចស្ត្រីនិងកុមារី ពីបទពេស្យាចារ ប៉ុន្តែ ច្បាប់ទាំងនោះ ក៏បានដាក់ទោសស្ត្រីដែលគួរតែទទួលបានការការពារទៅវិញ។ ស្ត្រីដែលពាក់ព័ន្ធមិនត្រឹមតែក្នុងការងារផ្តល់សេវាផ្លូវភេទប៉ុណ្ណោះទេ ថែមទាំងស្ត្រីនៅក្នុងផ្នែកណាមួយនៃឧស្សាហកម្មកំសាន្ត អាចត្រូវបានអាជ្ញាធរកាត់ទោសឬបៀតបៀន។ ស្ត្រីដែលគេសង្ស័យថាមានពាក់ព័ន្ធនឹងអំពើពេស្យាចារ ជារឿយៗ ត្រូវបានអាជ្ញាធរមូលដ្ឋាន បដិសេធមិនផ្តល់សេវាជាមូលដ្ឋានឲ្យ ត្រូវបានចាត់ទុកដូចជាឧក្រិដ្ឋជន សូម្បីតែពួកគេមិនបានរំលោភបំពានច្បាប់ដាក់លាក់ណាក៏ដោយ ព្រមទាំងត្រូវបានដាក់ឲ្យស្ថិតនៅក្នុងសភាពមានគ្រោះថ្នាក់ទៀតផង។ នៅដើមឆ្នាំ២០១៧ ស្ត្រីម្នាក់បានលង់ទឹកស្លាប់ បន្ទាប់ពីក្រុមសន្តិសុខខណ្ឌមួយក្រុម បានដេញនាងរហូតដល់ធ្លាក់ចូលក្នុងទន្លេ ដោយសារតែពួកគេសង្ស័យថានាងជាអ្នកផ្តល់សេវាផ្លូវភេទ។[26] ជាងនេះទៀត ដោយសារតែកង្វះការទទួលបានការថែទាំសុខភាពបន្តពូជដោយសុវត្ថិភាពនោះ អ្នកផ្តល់សេវាផ្លូវភេទ ទទួលរងគ្រោះដោយអាត្រាមរណមាតាក្នុងកម្រិតខ្ពស់ខុសពីធម្មតា ដែលជារឿយៗ ទាក់ទងនឹងការរំលូតកូន។[27]

3.6.2 ដើម្បីធានាឲ្យមានការទទួលបានយុត្តិធម៌ចំពោះស្ត្រីដែលធ្វើការនៅក្នុងឧស្សាហកម្មកំសាន្ត ឲ្យផុតពីការបំពាន ក្រមព្រហ្មទណ្ឌ មាត្រា២៩៨ និងច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទ មាត្រា២៣ និង២៤ គួរត្រូវធ្វើវិសោធនកម្ម ដើម្បីលុបបំបាត់ការដាក់ទណ្ឌកម្មសម្រាប់មនុស្សដែលត្រូវគេសង្ស័យថាជាអ្នកផ្តល់សេវាផ្លូវភេទ។ កិច្ចខិតខំខ្នែងក្នុងការប្រឆាំងការជួញដូរ គួរផ្តោតទៅលើមនុស្សដែលពាក់ព័ន្ធក្នុងការកេងប្រវ័ញ្ចទៅលើស្ត្រីនិងកុមារ គឺមិនត្រូវផ្តោតទៅលើអ្នកដែលត្រូវគេកេងប្រវ័ញ្ចនៅក្នុងឧស្សាហកម្មផ្លូវភេទនោះទេ។

- **3.6.3 អនុសាសន៍ស្នើឡើង ដើម្បីដោះស្រាយការរើសអើងទៅលើអ្នកផ្តលសេវាផ្លូវភេទ៖**
  ធ្វើការផ្សាយដំណឹងអំពីសេវាសាធារណៈឲ្យបានទូទាំងប្រទេស នៅតាមទូរទស្សន៍ វិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយ ត្រឹមឆ្នាំ២០២២ ដែលមានគោលបំណងប្រយុទ្ធប្រឆាំងនឹងផ្នត់គំនិតខុសឆ្គងនិងប្រឆាំងនឹងអំពើហិង្សាលើអ្នកផ្តល់សេវាផ្លូវភេទ ស្របជាមួយនឹង គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ១៦.១។
- **3.6.4 សំណួរស្នើត្រៀមទុកជាមុន ទាក់ងនឹងការរើសអើងទៅលើអ្នកផ្តល់សេវាផ្លូវភេទ៖**
  តើមានវិធានការអ្វីខ្លះដែលរដ្ឋាភិបាលបានដាក់ចេញ ដើម្បីធានាថាស្ត្រីដែលពាក់ព័ន្ធនឹងការងារផ្លូវភេទ មិនត្រូវបានគេផាត់ចេញនៅក្នុងសង្គម និងដើម្បីធានាថា ពួកគេត្រូវបានមន្ត្រីសន្តិសុខនិងមន្ត្រីអនុវត្តច្បាប់ ប្រព្រឹត្តដោយសមរម្យទៅលើពួកគេ?

## 3.7 ការអប់រំ៖

3.7.1 ប្រទេសកម្ពុជា បានបង្កើតដំណើរការដែលគួរឲ្យកត់សម្គាល់ដើម្បីដោះស្រាយភាពក្រីក្រ អំពើពុករលួយ កង្វះខាតសាលារៀននៅតំបន់ជនបទ ផ្នត់គំនិតយេនឌ័រតាមបែបប្រពៃណីដែលខុសឆ្គង ក្រឹត្យក្រមវប្បធម៌ និងកត្តាផ្សេងៗទៀតដែលបណ្តាលឲ្យមានគម្លាតរវាងការអប់រំរបស់ក្មេងស្រីនិងក្មេងប្រុស។ ក៏ប៉ុន្តែ ឧបសគ្គជាគន្លឹះ

មួយនោះគឺថា ទោះបីជាមានអនុសាសន៍ UPR នៅជុំមុនថា ការអប់រំត្រូវតែមានភាពចាំបាច់ដាច់ខាតសម្រាប់កុមារទាំងអស់ ដើម្បីឲ្យគ្រប់គ្នាបានទទួលការអប់រំក៏ដោយ ក៏ប្រទេសកម្ពុជាមិនបានតម្រូវឲ្យកុមារទៅចូលរៀនដែរ។ មិនមានប្រយោជន៍ណាមួយ ក្នុងការទប់ស្កាត់ឪពុកម្តាយមិនឲ្យបញ្ជូនកូនទៅសាលារៀននោះទេ។

3.7.2 ស្ត្រីមួយចំនួនត្រូវបានគេបង្ខំឲ្យរៀបការទាំងនៅវ័យក្មេង ស្ត្រីខ្លះទៀតត្រូវថែទាំគ្រួសារតាមប្រពៃណី ដែលបណ្តាលឲ្យសក្មេងស្រីឈប់រៀនមុនក្មេងប្រុស ជារឿយៗ ដើម្បីទៅធ្វើការនៅរោងចក្រ។ ប្រទេសកម្ពុជា ត្រូវបានវាយតម្លៃដាក់ចំណាត់ថ្នាក់ ១២៦/១៤៤ សម្រាប់ការចុះឈ្មោះចូលរួមនៅថ្នាក់មធ្យមសិក្សា ដូច្នេះ នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ។[28]

3.7.3 ទិន្នន័យដែលប្រមូលប្រចាំឆ្នាំ ដោយអង្គការអន្តរជាតិនិងដោយក្រសួងអប់រំក្នុងប្រទេសកម្ពុជា បានបង្ហាញថា ក្មេងប្រុសនិងក្មេងស្រីនៅក្នុងប្រទេសកម្ពុជា ចាប់ផ្តើមចូលរៀនក្នុងចំនួនស្មើគ្នា។[29] ដូចដែលយើងបានឃើញនៅក្នុងតារាងទី៣ និងទី៤ នៃស្ថិតិទិន្នន័យរបស់ក្រសួងអប់រំក្នុងប្រទេសកម្ពុជា មិនមានគម្លាតខុសគ្នារវាងក្មេងប្រុសនិងក្មេងស្រីនៅកម្រិតកុមារតូចនិងបឋមសិក្សានោះទេ។ របាយការណ៍បានបង្ហាញថា អាត្រាបោះបង់ការសិក្សារបស់សិស្សស្រី ចាប់ផ្តើមកើនឡើងពីថ្នាក់នៅពេលដែលពិន្ទុសិក្សាមានភាពល្អប្រសើរឡើង។ បាតុភូតនេះ កើតឡើងជាពិសេស នៅពេលសិស្សស្រីឈានដល់កម្រិតមធ្យមសិក្សា។ របាយការណ៍បានបង្ហាញថា គម្លាតយេនឌ័រក្នុងសាលាបឋមសិក្សាក្នុងតំបន់ជនបទនិងទីប្រជុំជន មានការថយចុះច្រើន ប៉ុន្តែអាត្រានៃការចុះឈ្មោះចូលរៀនសរុប មានការថយចុះខ្លាំងសម្រាប់សិស្សស្រីនៅក្នុងកម្រិតបឋមភូមិនិងទុតិយភូមិ។

3.7.4 កង្វះខាតការអប់រំកម្រិតឧត្តមសិក្សាសម្រាប់មនុស្សស្រី មានផលវិបាកសម្រាប់ការចូលរួមរបស់ស្ត្រីនៅក្នុងផ្នែកនយោបាយនិងកម្លាំងពលកម្ម។ តាមពិតទៅ ដោយសារតែភាពខុសគ្នានៃការអប់រំ រវាងយេនឌ័រនេះ វាបានបង្កឲ្យអវត្តមានអ្នកដឹកនាំជាស្ត្រី នៅក្នុងកម្រិតសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយ នៅក្នុងសង្គមកម្ពុជា។ កង្វះខាតនេះ បន្តឲ្យមានផ្នត់គំនិតអវិជ្ជមានទៅលើតួនាទីរបស់ស្ត្រីនៅក្នុងសង្គម។

- ❖ **3.7.5 អនុសាសន៍ស្នើឡើង ដើម្បីដោះស្រាយបញ្ហាអប់រំ៖**
  មុនឆ្នាំ២០២០ ត្រូវបង្កើតការអប់រំមិនបង់កម្រៃ ពេញម៉ោង និងមានគុណភាពខ្ពស់សម្រាប់កុមារទាំងអស់ ដោយរាប់បញ្ចូលទាំងការទទួលបានការអប់រំកុមារតូច នៅទូទាំងប្រទេស និងធ្វើឲ្យការអប់រំ ជាការចាំបាច់ដាច់ខាតសម្រាប់កុមារទាំងអស់។

## 3.8 ការងារ៖

3.8.1 កង្វះសមភាពសម្រាប់ស្ត្រីកម្ពុជានៅក្នុងកម្លាំងការងារ អាចចាត់ថ្នាក់ថាជាក្តីបារម្ភចម្បងមួយក្នុងចំណោមក្តីបារម្ភនានាសម្រាប់ស្ត្រីកម្ពុជា ដោយសារថា ចំនួនស្ត្រីដែលកំពុងមានការងារធ្វើ មានចំនួនស្ទើរតែស្មើនឹងចំនួនបុរសដែលកំពុងមានការងារធ្វើដែរ ប៉ុន្តែ ច្រើនតែនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធឬក្នុងតំណែងដែលទទួលបានប្រាក់កម្រៃទាបជាងបុរស។[30] ផលប៉ះពាល់យេនឌ័រដែលត្រូវបានប៉ាន់ប្រមាណនៅក្នុងរបាយការណ៍សហគមន៍សេដ្ឋកិច្ចអាស៊ាន បានកត់សម្គាល់អំពីតំណភ្ជាប់រវាងសមាហរណកម្មសេដ្ឋកិច្ចនិងភាពខុសគ្នានៃយេនឌ័រនៅក្នុងតំបន់អាស៊ាន ដែលធ្វើឲ្យមានស្ត្រីតិចតួចណាស់ដែលមានការងារនៅកម្រិតខ្ពស់ឬកម្រិតគ្រប់គ្រងនោះ។[31] ស្ត្រី

ភាគច្រើន ធ្វើការងារនៅផ្នែកទាបៗនៅខាងចុងនៃខ្សែសង្វាក់តម្លៃ ដែលជាទូទៅបំពេញតួនាទីជាស្មៀនឬផ្នែកលក់នៅត្រឹមកម្រិតចូលដំបូងប៉ុណ្ណោះ។

3.8.2 ស្ត្រីកម្ពុជា មានអាត្រាភាគរយខ្ពស់ក្នុងវិស័យកាត់ដេរ (៨០-៩០%) និង ៣០-៤០% នៃវិស័យសំណង់។ ភាគច្រើននៃកម្មករទាំងនេះ ជាអ្នកចំណាកស្រុកក្នុងប្រទេស ហើយអាចនឹងទទួលរងគ្រោះខ្លាំងចំពោះការប្រព្រឹត្តិមិនគប្បីនានា។ មានការយល់ឃើញទូលំទូលាយនិងមានភាពស៊ីសង្វាក់គ្នា ក្នុងប្រទេសនានា ដែលថាការងារសំណង់ជាការងារសម្រាប់បុរស ដែលស្ត្រីមិនមានសមត្ថភាពធ្វើការក្នុងវិស័យនេះទេ ហើយការងារនេះមិនសមរម្យសម្រាប់ស្ត្រីឡើយ។ លក្ខខណ្ឌការងារមិនល្អសម្រាប់ស្ត្រី គម្លាតប្រាក់ឈ្នួលតាមរយៈយេនឌ័រ ការបោះបង់ការងារកម្រិតខ្ពស់និងម៉ោងការងារមិនសមរម្យ (ដែលមានស៊ីសង្វាក់នឹងជីវិតគ្រួសារ) បានធ្វើឲ្យចំណែកការងាររបស់ស្ត្រីក្នុងវិស័យសំណង់ កាន់តែមានការលំបាក។ ជាលទ្ធផល យោងតាមរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិ "ក្នុងប្រទេសភាគច្រើន ការងារសំណង់ សឹងតែជាការងារផ្តាច់មុខរបស់បុរសទៅហើយ"។ ប៉ុន្តែ នៅក្នុងតំបន់មួយចំនួននៅអាស៊ី ស្ត្រីត្រូវបានគេផ្តល់ការងារឲ្យជាចំណែកមួយនៃគ្រួសារនៅក្នុងឧស្សាហកម្មសំណង់នេះ និងអាចរួមមានចំនួនមួយភាគបីនៃកម្លាំងការងារទាំងមូល ទោះបីជាមិនមាននៅក្នុងបញ្ជីឈ្មោះបើកប្រាក់ខែជាផ្លូវការ ឬដោយសារតែការពិចារណាជាពិសេសណាមួយក៏ដោយ។[32] ក្នុងន័យនេះ ស្ត្រីស្វែងរកការងារនៅក្នុងវិស័យសំណង់ ទោះបីជាមានការរើសអើងយេនឌ័រនៅកន្លែងការងារ ដោយសារតែកង្វះខាតជម្រើសផ្សេងទៀត ដោយសារតែស្ត្រីជាច្រើន មានជំនាញតិចតួចនិងជម្រើសការងារក៏មានចំនួនតិចតួចដែរ។

3.8.3 កត្តាប្រឈមសំខាន់មួយទៀតនៅក្នុងកន្លែងការងារសម្រាប់ស្ត្រីនោះ គឺការរីករាលដាលនៃការបៀតបៀនផ្លូវភេទ (រួមទាំង សម្តីនិងអាកប្បកិរិយា ដែលមានចេតនាក្នុងការប្រមាថស្ត្រីនិងធ្វើឲ្យអាម៉ាសដល់ស្ត្រី) នៅកន្លែងធ្វើការ។ ប្រទេសកម្ពុជា មិនមានច្បាប់ដែលមាននិយមន័យនិងការដាក់ទោសទណ្ឌច្បាស់លាស់សម្រាប់ការបៀតបៀនទាំងនេះនៅឡើយទេ ដូច្នេះ ជារឿយៗ វានាំឲ្យមិនមានការរាយការណ៍និងមិនមានការដាក់ទោសទណ្ឌអ្វីឡើយ។[33]

- **3.8.4 អនុសាសន៍ស្នើឡើង ដើម្បីដោះស្រាយបញ្ហាការងារ៖**
  **ត្រឹមឆ្នាំ២០២០ ត្រូវផ្តល់សច្ចាប័នទៅលើអនុសញ្ញាអន្តរជាតិស្តីពីការការសិទ្ធិកម្មករចំណាកស្រុកនិងក្រុមគ្រួសាររបស់ពួកគេ។**

**កំណត់សម្គាល់ចុងក្រោយ**

---

[1] អង្គការទាំងនោះមានដូចខាងក្រោមៈ

១ អង្គការស៊ីដ កម្ពុជា(NGO-CEDAW)

២ អង្គការ អាក់សិនអេត (AAC)

៣ អង្គការអនាគតយុវជនអាស៊ាន(Cam-ASEAN)

៤ អង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)

៥ បណ្ដាញយេនឌ័រនិងការអភិវឌ្ឍន៍ (GADNet)

៦ DanChurchAid, Cambodia (DCA)

៧ អង្គការយុវជនខ្មែរ និងការអភិវឌ្ឍសង្គម(KYSD)

៨ ជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី (LSCW)

៩ សហគមន៍ឥន្ទូកម្ពុជា (RoCK)

១១ អង្គការសីលាកា (SILAKA)

១២ ផ្ទះសាមគ្គី (SC)

១៣ បណ្ដាញការងារស្ត្រីរួបរួមគ្នា (WNU)

[2] អនុសាសន៍ទាំងនោះរួមមាន ១១៨.៦០ ១១៨.៦១ ១១៨.៦៦ ១១៨.៩៣ និង ១១៨.១០៤ ស្ដីអំពីការចាប់ខ្លួនតាមទំនើងចិត្ត លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ននិងពន្ធនាគារ (រួមទាំងអនីតិជន)។

[3] ម៉េច ដារ៉ា, "រដ្ឋាភិបាលបញ្ជូនថវិការចំនួន $១២៩លាន សម្រាប់ថវិការមូលដ្ឋាន" ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨, កាសែតភ្នំពេញប៉ុស្ដិ៍ https://phnompenhpost.com/national/government-transfers-massive-129m-local-budgets

[4] M. Jordanwood, "កិច្ចការពារដល់កុមារកម្ពុជា? តួនាទីរបស់គណៈកម្មការក្រុមប្រឹក្សាឃុំសង្កាត់សម្រាប់ស្ត្រីនិងកុមារ និងយន្តការការពារក្រៅប្រព័ន្ធសម្រាប់កុមារក្នុងសហគមន៍នៅកម្ពុជា" អង្គការ វើលវីសិន កម្ពុជា ខែមិនា ឆ្នាំ២០១៦។

[5] Taylor O'Connell, "របាយការណ៍បានលើកឡើងថា៖ រដ្ឋាភិបាលបានបរាជ័យក្នុងការផ្ដល់គាំទ្រដល់ស្ត្រី និងកុមារនៅថ្នាក់មូលដ្ឋាន" កាសែតកម្ពុជា ខេលី, ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦។

[6] កម្មវិធីផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីបានអនុវត្តក្រោមកិច្ចសហប្រតិបត្តិការជាមួយប្រទេសអាល៊ីម៉ង់ និងអូស្ត្រាលី ខណៈដែលសេវាផ្លូវច្បាប់ ការថែទាំសុខភាពបន្តពូជ និងសេវាសង្គមជាច្រើនទៀតត្រូវបានផ្ដល់ឲ្យសាធារណៈជនដោយអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ។ សមាជិករបស់អង្គការស៊ីដជាច្រើនដែលបានផ្ដល់បទសម្ភាសន៍ និងអង្គការអន្តរជាតិដែលបាននឹងកំពុងផ្ដល់សេវាជនរងគ្រោះដោយអំពើហិង្សាដែលកើតឡើងដោយភេទនិងឬកំពុងធ្វើការជាមួយអាជ្ញាធរមូលដានដោយផ្ទាល់បានបង្ហាញមតិគាំទ្រដល់របកគំហើញនេះ។

[7] របាយការណ៍តាមកាលកំណត់របស់រាជរដ្ឋាភិបាលដែលបានបញ្ជូនទៅគណៈកម្មការស៊ីដ ក្នុងកំឡុងខែមេសា ឆ្នាំ២០១៨ បានបញ្ជាក់ថានៅក្នុងចន្លោះរយៈពេល៣ឆ្នាំដែលគិតចាប់ពីឆ្នាំ២០១៤-១៦ នៅក្នុងទូទាំងប្រទេសកម្ពុជាមានដីការការពារចំនួនត្រឹមតែ១៩ដីការតែប៉ុណ្ណោះដែលបានចេញដោយតុលាការ ។ បន្ថែមលើនេះមានតែជាងពាក់កណ្ដាលនៃចំនួនខេត្តសរុបនៅក្នុងប្រទេសដែលបានបង្កើតទម្រង់និងប្រពន្ធរួចរាល់។

[8] ផែនការសកម្មភាពដែលគាំទ្ររួមដោយ ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានប្រកាសឲ្យអនុវត្តនៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៧

---

[9] របាយការណ៍ព្រាងរបស់ភាគីរាជរដ្ឋាភិបាលដែលបានបញ្ជូនទៅស៊ីដ កាលពីខែកញ្ញា ឆ្នាំ២០១៧ បានបញ្ជាក់ចំនួនប្រជាជនសរុបនៅក្នុងប្រទេសកម្ពុជាមានចំនួន ១៥.៥លាននាក់ នៅក្នុងឆ្នាំ២០១៦ ហើយ មានមេធាវីចំនួន១០១១នាក់ដែលបានចុះបញ្ជីនៅគណៈ មេធាវីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០១៧។

[10] គណៈកម្មការអ្នកច្បាប់អន្តរជាតិ "ការសិក្សាទិន្នន័យមូលដ្ឋានអំពីការទទួលបានយុត្តិធម៌ចំពោះទង្វើរំលោភសិទ្ធិមនុស្សជាប្រព័ន្ធនៅកម្ពុជា" ខែតុលា ឆ្នាំ២០១៧

[11] http://data.worldjusticeproject.org/. ការសិក្សាមិនបានផ្តល់ចំណាត់ថ្នាក់ដល់បណ្តាប្រទេសជាច្រើនរួមទាំងបណ្តាប្រទេសមួយចំនួននៅទ្វីបអាហ្វ្រិច និងមជ្ឈឹមបូពារដែលកំពុងមានសង្គ្រាមស៊ីវិលនោះ។

[12] គោលដៅកំណត់ដោយរបាយការណ៍របស់រដ្ឋាភិបាល នារីរតនៈទី៤ និងអង្គការសហប្រជាជាតិ។ សូមមើល https://sustainabledevelopment.un.org/sdgs សម្រាប់ព័ត៌មានបន្ថែមស្តីអំពី SDGs នៅកម្ពុជា។

[13] ត្រឹមរយៈពេលប៉ុន្មានខែក្រោយបន្ទាប់ពីសមាជិកក្រុមប្រឹក្សាឃុំសង្កាត់បានចូលកាន់ដំណែង គណបក្សប្រឆាំងធំនៅកម្ពុជាត្រូវបានរំលាយចោលនៅក្នុងឆ្នាំ២០១៧។ អ្នកនយោបាយទាំងអស់ដែលជាតំណាងរបស់គណបក្សប្រឆាំងនោះនៅថ្នាក់ជាតិ និងក្រោមជាតិក៏ត្រូវបានដកហូតដំណែង ហើយតំណែងននោះត្រូវចូលកាន់ជំនួសដោយតំណាងសមាជិកមកពីគណបក្សកាន់អំណាច និងគណបក្សតូចៗមួយចំនួនទៀត។

[14] មានតែខេត្តចំនួនមួយតែប៉ុណ្ណោះក្នុងចំណោមខេត្តទាំង២៥ ដែលមានអភិបាលខេត្តជាស្ត្រី ហើយគាត់ត្រូវបានតែងតាំងឲ្យកាន់តំណែងនោះនៅក្នុងឆ្នាំ២០១៧។

[15] Leonie Kijewski, "មានស្ត្រីតែពីររូបតែប៉ុណ្ណោះដែលបានចូលរួមនៅក្នុងរដ្ឋសភាជាតិ" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧។

[16] កម្ពុជាគ្មានការកំណត់ជាក់លាក់ជាលាយលក្ខណ៍អក្សរស្តីអំពីសមត្ថភាពរបស់អ្នកកាន់តួនាទីរដ្ឋាភិបាលនោះទេដូច្នេះហើយបានជាមានបុរសអសមត្ថភាពមួយចំនួនត្រូវបានជ្រើសតាំងឲ្យកាន់តំណែងតាមទំនៀមទំលាប់នោះ។

[17] អនុសាសន៍រួមលេខ ២៥ កថាខណ្ឌ២៣ របស់គណៈកម្មការស៊ីដបានបញ្ជាក់ថា៖
"ខណៈដែលវិធានការពិសេសបណ្តោះអាសន្នមានទិសដៅដើម្បីជម្រុញសម្រេចឲ្យបានភាពស្មើគ្នាដោយពេញលេញនោះសំណួរពាក់ព័ន្ធនិងសមត្ថភាពនិងគុណសម្បត្តិ ... ត្រូវតែត្រួតពិនិត្យដោយយកចិត្តទុកដាក់ចំពោះការលម្អៀងផ្នែកយេនឌ័រ ដោយសារតែការលម្អៀងនេះតែងតែកំណត់ដោយកត្តាវប្បធម៌និងបទដ្ឋានសង្គម។ សម្រាប់ការតែងតាំង ការជ្រើសរើស ឬការបោះឆ្នោត ដើម្បីចូលកាន់តំណែងនៅការិយាល័យសាធារណៈ និងនយោបាយ កត្តាផ្សេងៗក្រៅពីសមត្ថភាពនិងគុណសម្បត្តិ រួមទាំងការអនុវត្តនូវគោលការណ៍ប្រជាធិបតេយ្យស្មើភាព និងបោះឆ្នោតដោយសេរីក៏អាចជាកត្តាសំខាន់ដែរ។"

[18] ម៉េច ដារ៉ា "ចំនួនអ្នកជាប់ពន្ធនាគារកើនឡើងរហូតដល់២០ភាគរយ" ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ កាសែតភ្នំពេញប៉ុស្តិ៍ http://www.phnompenhpost.com/national/prison-numbers-jump-20-percent

[19] ម៉េច ដារ៉ា "ពន្ធនាគារព្រៃសនៅតែមានចំនួនអ្នកជាប់ពន្ធនាគារលើសចំណុះទោះបីជាមានពន្ធនាគារថ្មី២ត្រូវបានបង្កើតឡើងក៏ដោយ" ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ កាសែតភ្នំពេញប៉ុស្តិ៍ http://www.phnompenhpost.com/national/prey-sar-still-overcrowded-despite-two-new-prisons

[20] ចំនួនអ្នកជាប់ពន្ធនាគារជាក់លាក់នៅក្នុងពន្ធនាគារនិមួយៗមានបញ្ជាក់នៅក្នុងរបាយការណ៍របស់អង្គការលីកាដូ "សិទ្ធិមនុស្សឆ្នាំ២០១៧៖ ការត្រួតពិនិត្យប្រចាំឆ្នាំ" ខែកុម្ភៈ ឆ្នាំ២០១៨។

[21] http://www.prisonstudies.org/country/cambodia. ៧០% នៃចំនួនអ្នកជាប់ពន្ធនាគារអាចជាអ្នកដែលស្ថិតនៅក្នុងនីតិវិធីឃុំខ្លួនបណ្តោះអាសន្ន ឬ ជាអ្នកដែលកំពុងរងចាំសម្រេចចុងក្រោយរបស់តុលាការ.

[22] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានបញ្ជាក់អំពីមូលហេតុទាំងនោះ។

[23] ទោះបីជារាជរដ្ឋាភិបាលបានដោះលែងស្ត្រីនិងកុមាតូចៗជាច្រើនពីពន្ធនាគានៅក្នុងឆ្នាំ២០១៥ ចំនួននោះក៏បានកើនឡើងជាថ្មីហើយការកើនឡើងនោះគឺបានកើនឡើងលើសចំនួនស្ថិតិចាស់ទៀត។ គ្រាន់តែនៅក្នុងពន្ធនាគារចំនួន១៨ ដែលសមាជិកអង្គការស៊ីដគឺអង្គការលីកាដូបានឃ្លាំមើលនោះ មានកុមារចំនួន១០៨នាក់ និងស្ត្រីមានផ្ទៃពោះចំនួន៤១ នាក់ គិតមកត្រឹមខែតុលាឆ្នាំ២០១៧។ ហើយចំនួនកុមារបានកើនឡើងរហូតដល់ ១៨១នាក់ រីឯចំនួនស្ត្រីមានផ្ទៃពោះក៏បានកើនឡើងរហូតដល់៧៧នាក់គិតមកដល់ត្រឹមចុងខែធ្នូឆ្នាំ២០១៧។ ចំនួនកុមារបានធ្លាក់ចុះមកត្រឹម១៤៩នាក់ ហើយស្ត្រីមានផ្ទៃពោះបានធ្លាក់ចុះមកត្រឹម ២៣នាក់នៅក្នុងខែឧសភា ឆ្នាំ២០១៨។ ចំនួននេះមិនបានគិតបញ្ចូលចំនួនអនីតិជនដែលជាប់ចោទ ឬបានផ្តន្ទាទោសដោយបទល្មើសនោះទេ។ ក្នុងចំណោមស្ត្រី១៦៧នាក់ដែលបានជាប់ពន្ធនាគារក្នុងកំឡុងពេលមានផ្ទៃពោះ ឬក៏បានជាប់ពន្ធនាគារជាមួយកូនរបស់គាត់ម្នាក់ ឬកូនច្រើននាក់នោះ មានស្ត្រី៧៣នាក់ដែលកំពុងស្ថិតក្នុងនីតិវិធីឃុំខ្លួនបណ្តោះអាសន្នគិតមកត្រឹមខែឧសភា ឆ្នាំ២០១៨។

[24] ច្បាប់ស្តីពីពន្ធនាគារ ជាភាសាខ្មែរ និងអង់គ្លេសអាចទាញយកបានពីទីនេះ http://cambodia.ohchr.org/en/prison-reform/laws-pertaining-prisons

[25] សម្រាប់ព័ត៌មានបន្ថែមស្តីអំពីស្ថានភាពដែលស្ត្រីមានផ្ទៃពោះនិងកុមារនៅក្នុងពន្ធនាគារកម្ពុជាបានជួបប្រទះនោះសូមមើលរបាយការណ៍របស់អង្គការលីកាដូ “ម្តាយក្នុងពន្ធនាគារ៖ផលប៉ះពាល់នៃការឃុំខ្លួនចំពោះស្ត្រីនិងកុមារ” ខែឧសភា ឆ្នាំ២០១៥ https://www.licadho-cambodia.org/reports.php?perm=206

[26] សេក ឧត្តម "ស្ត្រីរកស៊ីផ្លូវភេទបានបាត់ខ្លួនក្នុងទន្លេបន្ទាប់ពីបានរត់គេចខ្លួនពីកងកម្លាំងរក្សាសន្តិសុខ" កាសែតកម្ពុជាឌៃលី ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៧

[27] Erin Handley, "គ្រោះថ្នាក់ដែលមើលមិនឃើញសម្រាប់ស្ត្រីរកស៊ីផ្លូវភេទ" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦។  សូមមើលផងដែរអំពី "មូលហេតុនៃការស្លាប់របស់ម្តាយនិងទារកក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ និងកូនៗរបស់ពួកគេ៖ ការសិក្សាប្រទាក់ក្រឡាមួយ" by Brian Willis, Saki Onda, and Hanni Marie Stoklosa, BMC Public Health, ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៦

[28] ស្ថិតិរបស់អង្គការ(UNESCO) វិទ្យាស្ថានស្ថិតិ សុច្ចនៈករស្តីការអប់រំ ប្រព័ន្ធទិន្នន័យ ឆ្នាំ២០១៦៖ http://uis.unesco.org.  Ranking is from The Global Gender Gap Index (2017) retrieved from http://www3.weforum.org/docs/WEF_GGGR_2017.pdf

[29] http://www.moeys.gov.kh/en/emis/2461.html#.Wwtvty_pPPA

[30] ក្រសួងកិច្ចការនារី ការវាយតម្លៃយេនឌ័រនៅកម្ពុជាឆ្នាំ២០១៤ គោលនយោបាយសង្ខេបស្តីពីសេដ្ឋកិច្ច៖ ការពង្រឹងសេដ្ឋកិច្ចរបស់ស្ត្រី http://www.kh.undp.org/content/dam/cambodia/docs/DemoGov/NearyRattanak4/Neary%20Rattanak%204%20-%20Women’s%20Economic%20Empowerment%20Eng.pdf

[31] របាយការណ៍របស់អគ្គលេខាធិការដ្ឋានអាស៊ានស្តីអំពីការគម្រោងដែលប៉ះពាល់ដល់សហគមន៍សេដ្ឋកិច្ចអាស៊ាន (ខែមិនា ឆ្នាំ២០១៦), ដកស្រងពី http://library.fes.de/pdf-files/bueros/singapur/12676.pdf

[32] អង្គការពលកម្មអន្តរជាតិ៖ កិច្ចប្រជុំត្រីភាគីស្តីអំពីឧស្សាហ៍កម្មសំណង់នៅក្នុងសតវត្សទី២១៖ រូបភាព ឱកាសការងារ និងជំនាញដែលត្រូវការ នៅទីក្រុងហ្សឺណែវ ឆ្នាំ២០០១

[33] មាត្រា២៥០នៃក្រមព្រហ្មទណ្ឌក្រោមប្រធានបទស្តីអំពី “អំពើហិង្សាផ្លូវភេទផ្សេងទៀត” ប្រើប្រាស់ពាក្យ អំពើបៀតបៀនផ្លូវភេទ ដើម្បីដាក់ទណ្ឌកម្មទោសទណ្ឌឲ្យជាប់ពន្ធនាគារយ៉ាងច្រើនត្រឹមតែ៣ខែ និងពិន័យជាប្រាក់ប៉ុណ្ណោះ ចំពោះទង្វើរំលោភអំណាចតាមរយៈការដាក់សំពាធជាបន្តបន្ទាប់ទៅលើបុគ្គលផ្សេងទៀតដើម្បីឲ្យគេរួមភេទ។